ចលនានិស្សិត
ដើម្បីលទ្ធិប្រជាធិបតេយ្យ

**បេសកកម្ម ២០២១**
ឯករាជ្យជាតិ និង សន្តិភាពផ្ទៃថ្លៃ
ទឹកដីព្រំដែន និង អន្តោប្រវេសន៍
សិទ្ធិមនុស្ស និង ប្រជាធិបតេយ្យ
យុត្តិធម៌សង្គម និង នីតិរដ្ឋស្អាតស្អំ

**ក្រុមប្រឹក្សាភិបាល**
លោក ម៉ែន ណាត ប្រធាន
លោក គឹម សុខ អនុប្រធាន

**គណៈកម្មាធិការប្រតិបត្តិ**
លោក ទូច វិបុល ប្រធាន
លោក អ៊ាប សេង អនុប្រធាន

STUDENT MOVEMENT FOR DEMOCRACY (SMD)

**Mission 2021**
National Independence and Peace
Sovereignty and Immigration
Human Rights and Democracy
Social Justice and Rule of law

**Leadership**
Men Nath, Chairman of BoD
Kim Sok, Vice Chairman of BoD
Vibol Touch, President
Eab Seng, Vice President

2402 24th St SE
Washington, DC 20020
t: 743-999-2110
e: smd2khmer@gmail.com
@: cambodiademocracy.org

*លេខ៖ ០០៧/២០២១ ច.ន.ប្រ.* រដ្ឋធានីវ៉ាស៊ីនតុន ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១

# សេចក្តីថ្លែងការណ៍

## រដ្ឋាភិបាលកម្ពុជា គួរស្នើមេដឹកនាំវៀតណាម ទទួលជនជាតិវៀតណាមខុសច្បាប់ ត្រឡប់ទៅវិញ

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** សូមអំពាវនាវដល់លោក **ហ៊ុន សែន** ប្រមុខនៃរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន គួរបង្ហាញសេចក្តីក្លាហាន ធ្វើលិខិតផ្លូវការស្នើទៅនាយករដ្ឋមន្ត្រីថ្មី នៃប្រទេសវៀតណាម លោក **Pham Minh Chinh** ដូចខាងក្រោម ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការ ជាមិត្តជិតខាងល្អ ៖

(១) រដ្ឋាភិបាលវៀតណាម ត្រូវតែទទួលយកជនជាតិរបស់ខ្លួន ដែលចូលមករស់នៅខុសច្បាប់ នៅប្រទេសកម្ពុជា ឲ្យត្រឡប់ទៅប្រទេសវៀតណាមទៅវិញ។

(២) រដ្ឋាភិបាលវៀតណាម ត្រូវតែបញ្ឈប់ការធ្វើទុក្ខបុកម្នេញ គ្រប់ទម្រង់លើពលរដ្ឋខ្មែរ នៅកម្ពុជាក្រោម ដែលជាម្ចាស់ទឹកដីកំណើតកម្ពុជាក្រោម ហើយត្រូវគោរពសិទ្ធិសេរីភាព របស់ពលរដ្ឋខ្មែរក្រោម តាមគោលការណ៍ធានាការពារដោយអង្គការសហប្រជាជាតិ។

(៣) រដ្ឋាភិបាលវៀតណាម ត្រូវតែគោរពច្បាប់សមុទ្រ ឆ្នាំ១៩៨២ **UNCLOS-1982** ដោយប្រគល់មកឲ្យប្រទេសកម្ពុជាវិញ នូវកោះត្រល់ ចង្កោមកោះក្រចកសេះ និងទំហំផ្ទៃទឹកសមុទ្រទាំងអស់របស់កម្ពុជា ដែលវៀតណាមកំពុងគ្រប់គ្រងទាំងខុសច្បាប់ ដូចដែលរដ្ឋាភិបាលវៀតណាម បានទាមទារឲ្យប្រទេសចិន គោរពច្បាប់សមុទ្រឆ្នាំ១៩៨២ ដែរ។

(៤) រដ្ឋាភិបាលដែលដឹកនាំដោយលោក **ហ៊ុន សែន** ត្រូវតែហ៊ានប្រកាសប្រាប់រដ្ឋាភិបាលថ្មីរបស់ប្រទេសវៀតណាមថា ក្នុងស្ថានភាពកម្ពុជាពុំមានឯកភាពជាតិ ប្រទេសកម្ពុជាត្រូវការផ្អាកការបោះបង្គោលព្រំដែនគោក ដែលនៅសល់ ជាមួយវៀតណាមសិន និង ក៏រក្សាសិទ្ធិសើរើឡើងវិញលើបង្គោលព្រំដែន ដែលបានបោះរួចហើយដែរ។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** យល់ឃើញថា ក្នុងកាលៈទេសៈដែលប្រទេសវៀតណាម ទើបតែរៀបចំរដ្ឋាភិបាលថ្មី គឺជាឱកាសល្អបំផុត សម្រាប់កម្ពុជា បញ្ជាក់អំពីជំហរច្បាស់លាស់ ដើម្បីការពារផលប្រយោជន៍របស់កម្ពុជា ទោះបីជាត្រូវធ្វើកិច្ចសហប្រតិបត្តិការជិតស្និទ្ធដល់ជម្រៅយ៉ាងណា ជាមួយវៀតណាមក៏ដោយ។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** ថ្កោលទោសនាយករដ្ឋមន្ត្រីវៀតណាម ដែលបានបង្ហាញគោលដៅបន្តរំលោភអធិបតេយ្យភាពនៃកម្ពុជា និងជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងកម្ពុជា នៅឯជំនួបទ្វេភាគីជាមួយលោក **ហ៊ុន សែន** នៅទីក្រុងចាការតា នៃប្រទេសឥណ្ឌូនេស៊ី ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២១។ នេះគឺជារឿងអយុត្តិធម៌ណាស់ សម្រាប់ប្រជាជាតិខ្មែរ នៅពេលលោក **Pham Minh Chinh** បានណែនាំប្រាប់លោក **ហ៊ុន សែន** ថា **« ... ឲ្យកម្ពុជាត្រូវបន្តផ្តល់ការគាំទ្រដល់សហគមន៍វៀតណាមនៅកម្ពុជា ជាពិសេសផ្តល់ឯកសារស្របច្បាប់នានា ដើម្បីជួយសម្រួលជនជាតិវៀតណាមទាំងនោះ ឱ្យមានលំនឹង ... »** ហើយលោក **ហ៊ុន សែន** បង្ហាញឥរិយាបថទទួលយក។

នាយករដ្ឋមន្ត្រីវៀតណាម បង្ហាញចរិតបន្តឈ្លានពានកម្ពុជា ដោយឥតអៀនខ្មាស ដូច្នេះយើងខ្ញុំ សូមលើកទឹកចិត្តលោក **ហ៊ុន សែន** ត្រូវហ៊ានប្រាប់មេដឹកនាំវៀតណាមវិញ អំពីកាតព្វកិច្ចរដ្ឋាភិបាលកម្ពុជា ដែលត្រូវការពារប្រយោជន៍របស់ប្រជាជាតិខ្មែរជាចាំបាច់ តាមគោលការណ៍នៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស៍ ឆ្នាំ១៩៩១ និងយុត្តាធិការច្បាប់អន្តរជាតិ។

**ប្រធានប្រតិបត្តិ**

**ទូច វិបុល**